# ការតម្លើងកម្មវិធីដាក់ក្នុងទូរសព្ទiPhone
# KH Taurus តាមទូរសព្ទដៃ
# វិធីសាស្ត្រតម្លើងកម្មវិធី iTunes

**KH Taurus Mobile-**គឺជាកម្មវិធីដែលបង្កើតឡើងសម្រាប់រង្វាយតម្លៃការផ្សំចំណីសម្រាប់គោសាច់នៅកម្ពុជា ដែលអាចប្រើជាមួយទូរសព្ទដៃ ជាភាសាអង់គ្លេស និងជាភាសាខ្មែរបាន។

## តម្រូវការរបស់ប្រព័ន្ធ

មុនពេលតម្លើងកម្មវិធី ត្រូវប្រាកដថាទូរសព្ទរបស់អ្នកត្រូវបំពេញតាមតម្រូវការដូចខាងក្រោម។ សម្រាប់ព័ត៍មានបន្ថែមអំពីលក្ខខណ្ឌនៃការតម្លើងកម្មវិធី សូមចូលទៅកាន់គេហទំព័រខាងក្រោម៖ https://geosoftware.faculty.ucdavis.edu/resources/

- **កម្មវិធីគ្រប់គ្រងឯកសារ (File Manager) –** អ្នកត្រូវការកម្មវិធីគ្រប់គ្រងឯកសារដើម្បីជាកន្លែងសម្រាប់ស្តុកទុកឯកសារដែលបានទាញយករួច។ សម្រាប់ទូរសព្ទ iOS មានកម្មវិធីគ្រប់គ្រងឯកសារផ្ទាល់ខ្លួនរួចជាស្រេច។ ប៉ុន្តែសម្រាប់ទូរសព្ទ Android អ្នកត្រូវការតំឡើងកម្មវិធីគ្រប់គ្រងឯកសារមួយផ្សេងទៀត។ កម្មវិធីគ្រប់គ្រងឯកសារឥតគិតថ្លៃល្អបំផុតគឺកម្មវិធីគ្រប់គ្រងឯកសារពីកម្មវិធី ASD Dev Video Player for All Format ដែលកម្មវិធីនេះអាចប្រើប្រាស់បានជាមួយវីដេអូគ្រប់ទម្រង់។
- **កម្មវិធី Google Docs –** កម្មវិធីទូរសព្ទរបស់យើងបង្កើតរបាយការណ៍ក្នុងទម្រង់ជា Rich Text (RTF) ហើយអ្នកត្រូវការកម្មវិធីពិនិត្យមើល RTF នៅលើទូរសព្ទរបស់អ្នក។ កម្មវិធីមើល RTF ឥតគិតថ្លៃល្អបំផុតគឺ Google Docs ។
- **ពុម្ពអក្សរ (Fonts) –** ដើម្បីមើលរបាយការណ៍ជាភាសាខ្មែរ អ្នកត្រូវតែតម្លើងពុម្ពអក្សរខ្មែរនៅលើទូរសព្ទរបស់អ្នក។
- **កម្មវិធី Google Gmail –** កម្មវិធីទូរសព្ទរបស់យើងផ្ញើរបាយការណ៍ដែលបានបង្កើតរួចជាឯកសារភ្ជាប់នៅក្នុងអ៊ីមែល ហើយអ្នកត្រូវមានកម្មវិធីអ៊ីមែលនៅលើទូរសព្ទរបស់អ្នក។ កម្មវិធីអ៊ីមែលឥតគិតថ្លៃល្អបំផុតគឺ Google Gmail ។
- **កម្មវិធី Google Chrome –** ដើម្បីប្រើ Google Docs និង Google Gmail ដោយមិនប្រើប្រាស់អ៊ីនធើ ណែត អ្នកត្រូវការកម្មវិធី Google Chrome នៅលើទូរសព្ទរបស់អ្នក។

## ការតម្លើងកម្មវិធី

ការប្រុងប្រយ័ត្ន – ប្រសិនបើអ្នកមានទម្រង់ចាស់នៃកម្មវិធី Taurus Mobile នៅលើទូរសព្ទ iPhone របស់អ្នក សូមលុបវាចោល មុនពេលតម្លើងកម្មវិធីថ្មីមួយនេះ។

មុននឹងដាក់ឱ្យប្រើប្រាស់កម្មវិធី iOS ជាសាធារណៈនៅលើ App Store យើងត្រូវដាក់ពង្រាយកម្មវិធីទាំងនេះទៅកាន់ក្រុមមនុស្សដែលមានចំនួនកំណត់សម្រាប់ការសាកល្បង។ ដើម្បីធ្វើវាបាន យើងត្រូវប្រើវិធីសាស្ត្រ Ad Hoc ហើយដាក់ឱ្យប្រើប្រាស់តាមអ៊ីនធើណែត។

### A – ការទាញទុកហ្វាលសម្រាប់តម្លើងក្នុងម៉ាស៊ីនរបស់អ្នក

ជាដំបូងត្រូវប្រើកម្មវិធីដើម្បីរុករកក្នុងការទាញយកទុកហ្វាល Apple IPA ទុកក្នុងម៉ាស៊ីនកំព្យូទ័ររបស់អ្នក។ ហ្វាល IPAមួយគឺពិសេសសម្រាប់ការតម្លើងក្នុងម៉ាស៊ីនមួយនៅក្នុង iOS devices។

1. នៅលើម៉ាស៊ីនកំព្យូទ័ររបស់អ្នក សូមចុចលើកម្មវិធីដើម្បីរុករក រួចចូលទៅកាន់គេហទំព័រកម្មវិធី GEO៖
   https://GEOSoftware.faculty.ucdavis.edu




2. រុករកទៅទំព័រក្នុងការទាញយក (Download page )
3. រំកិលចុះក្រោមទៅផ្នែក iOS
4. រំកិលចុះក្រោមទៅកាន់កម្មវិធីផ្សំចំណីគោសាច់សម្រាប់ប្រទេសកម្ពុជា




5. ចុចលើ IPA package បន្ទាប់មករក្សាទុកវាក្នុងម៉ាស៊ីនកំព្យូទ័ររបស់អ្នក
6. សូមប្រាកដនិងចំណាំកន្លែងដែលអ្នកបានរក្សាវាទុកនៃឈ្មោះនេះ **edu.ucdavis.gfx.tau.ph.ipa**

## B. **ការតម្លើង Apple ITunes នៅក្នុងម៉ាស៊ីនកំព្យូទ័រ**

ជំហានបន្ទាប់មកក្នុងការតម្លើង Apple ITunes នៅក្នុងម៉ាស៊ីនកំព្យូទ័រ

1. សូមចុចលើកម្មវិធីដើម្បីរុករកលើគេហទំព័រផ្លូវការរបស់ Apple សម្រាប់ទាញទុក iTunesនៅលើ https://support.apple.com/downloads/itunes
2. ផ្ទាំងខាងក្រោមលេចឡើង




3. ទាញទុក iTunes សម្រាប់ Windows ទាំងទំរង់ 32bit ឬ 64-bit
4. តម្លើង iTunes នៅក្នុងម៉ាស៊ីនរបស់អ្នក

## C – ប្រើ iTunesសម្រាប់តម្លើងកម្មវិធីiOS នៅលើiPhoneរបស់អ្នក

1. ដាក់ឱ្យដំណើរការ iTunes នៅក្នុងម៉ាស៊ីន។ ផ្ទាំងសំខាន់របស់ iTunes លេចឡើង




2. បញ្ជាក់ថានៅផ្នែកខាងឆ្វេងមិនមានលេចបង្ហាញកម្មវិធីអ្វីទាំងអស់
3. ភ្ជាប់ iPhoneរបស់អ្នកទៅម៉ាស៊ីនកំព្យូទ័រជាមួយខ្សែ USB ដែលអ្នកប្រើសម្រាប់បញ្ចូលថាមពលទូរសព្ទ
4. ផ្ទាំងសារមួយលោតឡើង សួរអ្នកថាតើអ្នកអនុញ្ញាតិឱ្យម៉ាស៊ីនកំព្យូទ័រនេះទទួលបានព័ត៌មាននៅក្នុងទូរសព្ទ iPhone ដូចបង្ហាញខាងក្រោម៖




5. ចុចប៊ូតុងបន្ត
6. ចូលទៅទូរសព្ទ iPhoneរបស់អ្នក ហើយអនុញ្ញាតិឱ្យម៉ាស៊ីនកំព្យូទ័រនេះទទួលបានព័ត៌មាននៅក្នុងទូរសព្ទ iPhoneរបស់អ្នក
7. បន្ទាប់ពីអ្នកបានអនុញ្ញាតិរួចហើយ iTunes ចាប់ផ្តើមភ្ជាប់ទូរសព្ទ iPhoneរបស់អ្នកទៅម៉ាស៊ីនកំព្យូទ័ររបស់អ្នក

8. នៅពេលដែលការភ្ជាប់នេះរួចរាល់ iTunes បង្ហាញការភ្ជាប់បានទូរសព្ទ iPhone នៅផ្នែកខាងឆ្វេង ដូចបង្ហាញខាងក្រោម៖




9. បន្ទាប់ពីទូរសព្ទ iPhone បានភ្ជាប់ទៅម៉ាស៊ីនកំព្យូទ័រ សូមចុចចូលទៅក្នុងម៉ាស៊ីនកំព្យូទ័ររបស់អ្នកទៅរកហ្វាលដែលអ្នកបានទាញទុកសម្រាប់តម្លើង edu.ucdavis.gfx.tau.ph.ipa.
10. ចម្លងទុកហ្វាល ipa
11. ចុចម៉ៅខាងស្តាំទៅលើឈ្មោះ iPhone នៅផ្នែកខាងឆ្វេងរបស់ iTunes ហើយ Paste ហ្វាលតម្លើងនៅទីនោះ
12. សូមប្រាកដថាអ្នកបានចុចម៉ៅខាងស្តាំទៅលើឈ្មោះ iPhone ហើយមិនស្ថិតនៅលើកន្លែងណាផ្សេងទៀត
13. សារដំណើរការមួយនឹងលេចឡើងនៅផ្នែកខាងលើអេក្រង់របស់ iTurne ដូចបានបង្ហាញខាងក្រោម៖




14. បន្ទាប់ពីតម្លើងរួចរាល់ សូមចូលទៅទូរសព្ទ iPhone របស់អ្នក ហើយអ្នកនឹងឃើញរូបតំណាងកម្មវិធីបង្ហាញដូចខាងក្រោម៖




15. អ្នកអាចឃើញសារកំហុសមួយនៅបន្ទាប់ពីរូបតំណាង PH Taurus Mobile app ដូចបង្ហាញខាងក្រោម។ សារកំហុសនេះមានន័យថាពួកយើងមិនមាន UDID នៃទូរសព្ទរបស់អ្នកនៅក្នុងបញ្ជីម៉ាស៊ីនរបស់យើងឡើយ។ សូមបន្តធ្វើទៀតទៅតាមការណែនាំទទួលបាន UDID និងសូមផ្ញើរ UDID របស់អ្នកមកក្រុមការងារយើង។ នៅពេលដែលយើងទទួលបាន UDID របស់អ្នក យើងនឹងបញ្ចូលទូរសព្ទiPhoneរបស់អ្នកនៅក្នុងបញ្ជីម៉ាស៊ីនរបស់យើង។




## របៀបបើកដំណើរការ

1. នៅពេលដែលកម្មវិធីត្រូវបានដំឡើងនៅលើ iPhone របស់អ្នក សូមចុចរូបតំណាងរបស់កម្មវិធី (app icon) ។ វានឹងលោតសារដាស់តឿន ដែលស្នើរឱ្យអ្នកបើកដំណើរការ Developer Mode។ រួចចុចប៊ូតុង OK ។
2. ចូលទៅកាន់ Settings រួចចូលទៅកាន់ Privacy & Security > Developer Mode។
3. ចូលទៅកាន់ការកំណត់ Developer Mode
4. ចុចលើប៊ូតុងបិទបើក។ អ្នកនឹងទទួលបានសារពី iOS ដើម្បីចាប់ផ្ដើមដំណើរការឡើងវិញនូវម៉ាស៊ីន (Device) របស់អ្នក។ រួចចុចលើប៊ូតុង Restart ។
5. បន្ទាប់ពីម៉ាស៊ីនចាប់ផ្ដើមឡើងវិញ សូមដោះសោម៉ាស៊ីនរបស់អ្នក។ ការជូនដំណឹងពីប្រព័ន្ធនឹងលេចឡើង។ ចុចបើក ហើយបន្ទាប់មក បញ្ចូលលេខកូដសម្ងាត់ម៉ាស៊ីនរបស់អ្នក។
6. នោះ Developer Mode នឹងត្រូវបានបើកដំណើរការបាន។ ពេលនេះអ្នកអាចធ្វើអន្តរកម្មទំហំផ្ទុកខាងក្នុងជាមួយម៉ាស៊ីនទូរសព្ទ និងការបង្កើតដើម្បីរក្សាទុកក្នុងម៉ាស៊ីនរបស់អ្នក។

អ្នកអាចបិទ Developer Mode នៅពេលណាក៏បាន ប៉ុន្តែត្រូវចំណាំថាអ្នកនឹងត្រូវធ្វើតាមដំណើរការដដែលនេះម្ដងទៀតដើម្បីបើកវាឡើងវិញ។ តំណភ្ជាប់ទៅកាន់វីដេអូនៃការបង្រៀនបើកប្រើប្រាស់ Developer Mode នៅក្នុង YouTube https://www.youtube.com/watch?v=HfZuVFfqruc